**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គិសនីកម្ពុជា**

លេខ : ២៩៣២ សជល·អក·មអជ

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង

**អគ្គិសនីកម្ពុជា** មានកិត្តិយសជម្រាបជូនអ្នកកាន់អាជ្ញាប័ណ្ណចែកចាយអគ្គិសនីឲ្យបានជ្រាបថា៖ **រាជរដ្ឋាភិបាលកម្ពុជា** បានដាក់ចេញនូវផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៥-២០២០ ដោយមានគោលដៅគ្របដណ្តប់លើតំបន់ផ្គត់ផ្គង់អគ្គិសនីទាំងឡាយ ដែលប្រភពអគ្គិសនីផ្តល់ពីបណ្តាញជាតិ ដើម្បីបន្ថយអត្រាថ្លៃលក់អគ្គិសនីទូទៅ និងអ្នកប្រើប្រាស់មានជីវភាពក្រីក្រប្រើអគ្គិសនីតិច រួមទាំងសម្រាប់ការប្រើប្រាស់បូមទឹកធ្វើកសិកម្មនៅពេលយប់ផងដែរ។ យន្តការចំបងនៃការអនុវត្តផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី គឺនាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទនៃអគ្គិសនីកម្ពុជា (បន្ទាប់ពីនេះទៅហៅថា "ម.អ.ជ.") ទទួលបន្ទុកផ្តល់ថវិកាឧបត្ថម្ភធនតាម "អត្រាថ្លៃឧបត្ថម្ភធន" ប៉ះប៉ូវបង្គ្រប់ "អត្រាថ្លៃពិត" ដល់អ្នកកាន់អាជ្ញា-ប័ណ្ណ។ "អត្រាថ្លៃពិត" គឺជាអត្រាថ្លៃដែលបានពីការគណនា ដោយឈរលើមូលដ្ឋាននៃការចំណាយសមរម្យស្របទៅតាមគោលការណ៍ដែលកំណត់ដោយច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិ និងដែលកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា។ "អត្រាថ្លៃឧបត្ថម្ភធន" គឺជាអត្រាថ្លៃដែលបានមកពីការកំណត់ឲ្យទាបជាង "អត្រាថ្លៃពិត" ដោយប្រើថវិកាឧបត្ថម្ភធនប៉ះប៉ូវឲ្យអ្នកធ្វើអាជីវកម្មអគ្គិសនី ដើម្បីឲ្យអ្នកធ្វើអាជីវកម្មទទួលបានចំណូលដូចការលក់តាម "អត្រាថ្លៃពិត" ដែរ។

ដើម្បីទទួលបានថវិកាឧបត្ថម្ភធនមកប៉ះប៉ូវថ្លៃរបស់ខ្លួនវិញ អ្នកកាន់អាជ្ញាប័ណ្ណចែកចាយអគ្គិសនីត្រូវដាក់ពាក្យសុំថវិកាឧបត្ថម្ភធនទៅ ម.អ.ជ. នៅដំណាច់ខែនីមួយៗ ដោយភ្ជាប់ជាមួយនូវព័ត៌មាន៖ ១- ការទិញ និងផលិតអគ្គិសនីដោយមានច្បាប់ចម្លងនៃឯកសារដែលបង្ហាញអំពីការងារទាំងនេះ ២- ចំនួនលក់សរុបឲ្យអ្នកប្រើប្រាស់ប្រភេទខុសៗគ្នា និង ៣- ការលក់អគ្គិសនីឲ្យប្រភេទអ្នកប្រើប្រាស់តាមអត្រាថ្លៃឧបត្ថម្ភធន និងតារាងគណនាចំនួនថវិកាដែល ម.អ.ជ. ត្រូវឧបត្ថម្ភធន តាមគំរូដែលបានភ្ជាប់មកជាមួយនៅឧបសម្ព័ន្ធទី១ ទី២ និងទី៣ នៃសេចក្តីសម្រេចស្តីពីការកំណត់នីតិវិធីសម្រាប់អនុវត្តការឧបត្ថម្ភធន ដើម្បីបន្ថយថ្លៃអគ្គិសនីលេខ ០១១សរ.១៦អអក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦ ដូចមានភ្ជាប់មកជាមួយ។ អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់នូវព័ត៌មានខាងលើនេះឲ្យបានគ្រប់គ្រាន់ និងឲ្យបានត្រឹមត្រូវ ដើម្បីឲ្យថវិកាឧបត្ថម្ភធនអាចផ្ទេរទៅគណនីរបស់អ្នកកាន់អាជ្ញាប័ណ្ណទាន់ពេល។

ផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនេះ ចាប់ផ្តើមអនុវត្តន៍លើថាមពលអគ្គិសនីដែលប្រើប្រាស់នៅខែមីនា ឆ្នាំ២០១៦ តទៅ។

ព័ត៌មានបន្ថែមសូមទំនាក់ទំនងលោក គីម ឬទ្ធី ទូរស័ព្ទលេខ 016 586-633 ឬ លោក ថាច់ កៀងមុនី ទូរស័ព្ទលេខ 016 988-685 ឬទាក់ទងមក ម.អ.ជ. ទូរស័ព្ទលេខ 023 997-600 ឬទូរសារលេខ 023 997-601 ឬអញ្ជើញមកទំនាក់ទំនងនៅនាយកដ្ឋាន ម.អ.ជ. មានទីតាំងនៅអាគារលេខ២០៥ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

**កែវ រតនៈ**

**ចម្លងជូន៖**
- អាជ្ញាធរអគ្គិសនីកម្ពុជា
- អគ្គនាយករងអគ្គិសនីកម្ពុជា ដើម្បី "ជាព័ត៌មាន"
- ឯកសារ-កាលប្បវត្តិ